**ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់របស់ ADB**
**ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិក៖**
**ការអភិវឌ្ឍជើងឯកផ្នែកនីតិបរិស្ថាន**
**កម្មវិធីការបណ្តុះបណ្តាលគ្រូបង្គោល**
**ថ្ងៃទី ២៧ ខែ វិច្ឆិកា - ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧**
**ខេត្តសៀមរាប ប្រទេសកម្ពុជា**

## លិខិតយល់ព្រមចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សា ការយល់ព្រមទទួលខុសត្រូវលើហានិភ័យដោយខ្លួនឯង និងឱ្យអ្នករៀបចំកម្មវិធីរួចផុតពីបន្ទុកទទួលខុសត្រូវ

ធនាគារអភិវឌ្ឍអាស៊ី (ADB) បានអនុម័តលើគម្រោងជំនួយបច្ចេកទេសថ្នាក់តំបន់ ដើម្បីពង្រឹងនីតិបរិស្ថានក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈការអភិវឌ្ឍជើងឯកផ្នែកនីតិបរិស្ថានតាមរយៈកម្មវិធីការបណ្តុះបណ្តាលគ្រូបង្គោល ("កម្មវិធី TTT")។ ADB បានជ្រើសរើសសាស្ត្រាចារ្យ និងគ្រូឧទ្ទេសផ្នែកច្បាប់មកពីប្រទេសកម្ពុជា និងប្រទេសឡាវ ដើម្បីចូលរួមក្នុងកម្មវិធី TTT ក្នុងប្រទេស ដែលត្រូវធ្វើឡើងនៅខេត្តសៀមរាប ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ២៧ ខែ វិច្ឆិកា - ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧ ("កម្មវិធី TTT ទី ៨")។ កម្មវិធី TTT ទី ៨ ត្រូវបានអនុវត្តដោយបណ្ឌិតសភា IUCN ផ្នែកនីតិបរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា រួមគ្នាជាមួយ ADB។

ជាផ្នែកមួយនៃកម្មវិធី TTT ទី ៨ ADB និងបណ្ឌិតសភា IUCN នៃនីតិបរិស្ថាន នឹងធ្វើទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលអភិរក្សជីវៈសាស្ត្រចម្រុះអង្គរ (ACCB) នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ចាប់ពីម៉ោង ១:៣០ នាទីល្ងាច ដល់ម៉ោង ៥:៣០ នាទីល្ងាច ដើម្បីអនុវត្តបង្ហាញអំពីទស្សនកិច្ចសិក្សាជាវិធីសាស្ត្របង្រៀន និងដើម្បីរៀនសូត្រអំពីគោលនយោបាយបរិស្ថាន និងបញ្ហាផ្នែកច្បាប់នានាទាក់ទងជាមួយការអភិរក្សសត្វព្រៃ។

ឯកសារនេះពិពណ៌នាជូនជ្រាបអំពីដំណើរទស្សនកិច្ចសិក្សា និងផ្តល់ការបញ្ជាក់លើកាតព្វកិច្ចមួយចំនួន ព្រមទាំងឱ្យម្ចាស់កម្មវិធីរួចផុតពីបន្ទុកការទទួលខុសត្រូវ និងការលះបង់សិទ្ធិមិនទាមទារឱ្យ ADB បណ្ឌិតសភាព IUCN ផ្នែកនីតិបរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ត្រូវទទួលខុសត្រូវចំពោះរូបអ្នក។ សូមអានទម្រង់នេះដោយប្រុងប្រយ័ត្នមុនពេលចុះហត្ថលេខា។

១.	ខ្ញុំនឹងចូលរួមក្នុងទស្សនកិច្ចសិក្សាទៅតាមកាលវិភាគធ្វើដំណើរដូចមានស្នើឡើងខាងក្រោម៖

| | | |
|---|---|---|
| ១.១៥ – ១:៣០ | បទបង្ហាញអំពីទស្សនកិច្ចសិក្សា៖<br>• ការពន្យល់អំពីឯកសារព័ត៌មាន<br>• ការផ្តល់ព័ត៌មានសង្ខេបអំពីសុវត្ថិភាព/សន្តិសុខ | Georgina Lloyd |
| ១.៣០ – ២.៣០ | ធ្វើដំណើរតាមរថយន្តក្រុងទៅកាន់ទីតាំងទស្សនកិច្ចសិក្សានៅក្បាលស្ពាន ក្នុងឧទ្យានជាតិភ្នំគូលែន។ | |
| ២.៣០ – ៣.០០ | ការផ្តល់ព័ត៌មានសង្ខេបស្តីពីបញ្ហានានាក្នុងដំណើរទស្សនកិច្ចសិក្សា | Georgina Lloyd<br>Michael Mayerhoff,<br>Project Manager, ACCB |
| ៣.០០ – ៤.៣០ | ការចុះទស្សនកិច្ចសិក្សានៅ ACCB | |
| ៤.៣០ – ៥.៣០ | វគ្គផ្តល់យោបល់ត្រឡប់ក្រោយទស្សនកិច្ច (នៅទីតាំងបណ្តុះបណ្តាល)៖<br>• ពិភាក្សាលើបញ្ហាផ្នែកច្បាប់ និងគោលនយោបាយកើតមានពីទីតាំងទស្សនកិច្ចសិក្សា<br>• ពិភាក្សាអំពីដំណើរទស្សនកិច្ចក្នុងនាមជាវិធីសាស្ត្របង្រៀន រួមទាំងសនិទានភាព ការពិចារណាផ្នែកឡូជីស្ទីក បញ្ហាផ្នែកសុវត្ថិភាព និងមុខងារនៃការផ្តល់យោបល់ត្រឡប់ក្រោយដំណើរទស្សនកិច្ច។ | All trainers + Michael Mayerhoff |
| ៥.៣០ – ៦.៣០ | ធ្វើដំណើរតាមរថយន្តក្រុងវិលត្រឡប់ទៅកន្លែងពិសារអាហារពេលល្ងាច | |

២.	ខ្ញុំយល់ច្បាស់ថា ការចូលរួមរបស់ខ្ញុំក្នុងដំណើរទស្សនកិច្ចសិក្សាដូចមានបញ្ជាក់ខាងលើ អាចមានលទ្ធភាពកើតមានហានិភ័យមួយចំនួន ឬហានិភ័យនៃការរងរបួស។ ខ្ញុំមានឆន្ទៈទទួលខុសត្រូវ និងទទួលយកហានិភ័យដូចដែលបានពោលដោយខ្លួនឯង ហើយយល់ព្រមថា សុវត្ថិភាពរបស់ខ្ញុំគឺអាស្រ័យជាចម្បងលើការមើលថែខ្លួនខ្ញុំឱ្យបានត្រឹមត្រូវ និងអនុវត្តការប្រុងប្រយ័ត្នខ្ពស់។

៣.	ខ្ញុំយល់ច្បាស់ថា ADB បណ្ឌិតសភា IUCN ផ្នែកច្បាប់បរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ពុំតំណាងឱ្យ ឬធ្វើសកម្មភាពជាភ្នាក់ងារ និងមិនអាចគ្រប់គ្រងលើទង្វើ ឬការមិនអនុវត្តតាមរបស់អ្នកដឹកជញ្ជូន ឬអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាដទៃទៀតដែលពាក់ព័ន្ធក្នុងដំណើរទស្សនកិច្ចសិក្សានេះឡើយ។ ខ្ញុំយល់ច្បាស់ថា ADB បណ្ឌិតសភា IUCN នៃច្បាប់បរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ពុំទទួលខុសត្រូវលើបញ្ហានានាដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ខ្លួនឡើយ។

៤. ADB នឹងជម្រាបព័ត៌មានសង្ខេបអំពីសុវត្ថិភាព និងសន្តិសុខនៅមុនពេលចុះទស្សនកិច្ចសិក្សា ហើយមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជានឹងផ្តល់បុគ្គលម្នាក់បានទទួលការបណ្តុះបណ្តាលផ្នែកសង្គ្រោះបឋម ឱ្យធ្វើដំណើរជាមួយសិក្ខាកាមក្នុងពេលទស្សនកិច្ចសិក្សាទាំងមូល។ ទោះយ៉ាងណាក្តី ខ្ញុំទទួលស្គាល់ថាខ្ញុំជាអ្នកទទួលខុសត្រូវចំពោះតម្រូវការផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួនដោយខ្លួនឯង។ ខ្ញុំពុំមានមូលហេតុ ឬបញ្ហាពាក់ព័ន្ធជាមួយសុខភាព ដែលរារាំងការចូលរួមរបស់ខ្ញុំក្នុងដំណើរទស្សនកិច្ចសិក្សានេះឡើយ។

៥. ខ្ញុំយល់ច្បាស់ថា គ្រោះថ្នាក់/ការធានារ៉ាប់រងសុខភាព/ការធានារ៉ាប់រងការធ្វើដំណើរ គឺជាការទទួលខុសត្រូវរបស់ខ្ញុំផ្ទាល់ ហើយខ្ញុំអះអាងថា ខ្ញុំត្រូវបានគ្រប់ដណ្តប់ដោយការធានារ៉ាប់រងសុខភាពដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការណាមួយ និងសេចក្តីត្រូវការទាំងអស់ ឬការបង់ប្រាក់សម្រាប់ការចំណាយផ្នែកវេជ្ជសាស្ត្រ ពេលដែលខ្ញុំចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានេះ។ ខ្ញុំទទួលស្គាល់ថា ADB បណ្ឌិតសភា IUCN ផ្នែកនីតិបរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ពុំមានកាតព្វកិច្ចត្រូវទទួលខុសត្រូវលើតម្រូវការផ្នែកវេជ្ជសាស្ត្រ ឬការព្យាបាលរបស់ខ្ញុំឡើយ ហើយខ្ញុំទទួលយក និងទទួលខុសត្រូវចំពោះហានិភ័យទាំងអស់។ ប្រសិនបើខ្ញុំត្រូវការការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬការថែទាំដោយមន្ទីរពេទ្យក្នុងពេលចុះទស្សនកិច្ចសិក្សា ADB បណ្ឌិតសភា IUCN នៃច្បាប់បរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ពុំទទួលខុសត្រូវចំពោះការចំណាយ ឬគុណភាពនៃការចំណាយ ឬការថែទាំទាំងនេះឡើយ។

៦. ខ្ញុំយល់ព្រមទទួលខុសត្រូវធ្វើយ៉ាងណាឱ្យខ្លួនខ្ញុំមានការធានារ៉ាប់រងការធ្វើដំណើរផ្ទាល់ខ្លួនរបស់ខ្ញុំ ឱ្យបានមុនពេលកម្មវិធី TTT ទី ៨ ចាប់ផ្តើម។

៧. ក្នុងករណីមានបញ្ហាអាសន្នផ្នែកវេជ្ជសាស្ត្រ ខ្ញុំសូមផ្តល់សិទ្ធិដល់ ADB និងបណ្ឌិតសភា ផ្នែកនីតិបរិស្ថាន ទំនាក់ទំនងទៅ៖

ឈ្មោះ៖

ត្រូវជា៖

លេខទូរស័ព្ទ៖

អ៊ីម៉េល៖

៨. ខ្ញុំយល់ព្រមគោរពតាមច្បាប់ និងការអនុវត្តនានាដែលត្រូវអនុវត្ត ដើម្បីកាត់បន្ថយហានិភ័យនៃការរងរបួស ហើយខ្ញុំយល់ព្រមឈប់ និងស្វែងរកជំនួយ ប្រសិនបើខ្ញុំមិនជឿជាក់ថាខ្ញុំអាចបន្តដំណើរទស្សនកិច្ចសិក្សាបានដោយសុវត្ថិភាព។ ខ្ញុំយល់ព្រមដាក់កម្រិតលើការចូលរួមរបស់ខ្ញុំ ដើម្បីឆ្លុះបញ្ចាំងលើកម្រិតភាពសមស្របនៃសុខភាពរបស់ខ្ញុំ។

៩. ខ្ញុំទទួលស្គាល់ថា នៅក្រោម ‟កិច្ចព្រមព្រៀងបង្កើតធនាគារអភិវឌ្ឍអាស៊ី″ ADB បានទទួលសិទ្ធិនិទណ្ឌភាពពីដំណើរការផ្នែកច្បាប់ក្នុងទម្រង់ភាគច្រើន ហើយអភិបាល នាយក អ្នកជំនួស មន្ត្រី និងនិយោជិតរបស់ ADB ទាំងអស់ រួមទាំងជំនាញការដែលកំពុងអនុវត្តបេសកកកម្មសម្រាប់ ADB រួចផុតពីដំណើរការផ្នែកច្បាប់ទាក់ទងជាមួយសកម្មភាពដែលពួកគេអនុវត្តនៅក្នុងសមត្ថភាពផ្លូវការរបស់ខ្លួន លើកលែងតែ ADB បោះបង់និទណ្ឌភាពនេះ។ ពុំមានចំណុចណាមួយក្នុងឯកសារនេះនឹងមានប្រតិបត្តិការ ឬត្រូវបានបកស្រាយជាការបោះបង់សិទ្ធិ ការលះបង់ ឬការកែសម្រួលដទៃទៀតណាមួយទៅលើអភ័យឯកសិទ្ធិ ឬនិទណ្ឌភាពរបស់ ADB ក្រោម ‟កិច្ចព្រមព្រៀងបង្កើតធនាគារអភិវឌ្ឍអាស៊ី″ នោះឡើយ។

១០. អនុលោមតាមចំណុចដូចបានលើកឡើងខាងលើ ខ្ញុំសូមបោះបង់សិទ្ធិ និងលះបង់រាល់ការទាមទារទាំងអស់ប្រឆាំង ADB បណ្ឌិតសភា IUCN ផ្នែកច្បាប់បរិស្ថាន និងមហាវិទ្យាល័យច្បាប់ និងកិច្ចការសាធារណៈរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងនិយោជិត ឬភ្នាក់ងាររបស់ស្ថាប័នទាំងនេះ ដែលបង្កឡើងដោយការខកខានរបស់ខ្ញុំក្នុងការអនុវត្តតាមច្បាប់ បទដ្ឋាន និងការណែនាំទាក់ទងជាមួយដំណើរទស្សនកិច្ចសិក្សានេះ។

ឈ្មោះ៖ ______________________________________________

ហត្ថលេខា៖ ___________________________________________

កាលបរិច្ឆេទ៖ _______________________